ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៣៣៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៧៩៩ ហិកតា ស្ថិតក្នុងភូមិសាស្ត្រស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០២២/១២៣៦ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២២ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា១ .-**

ធ្វើអនុបយោគផ្ទៃដីសាធារណៈរបស់រដ្ឋទំហំ ៧៩៩ (ប្រាំពីររយកៅសិបប្រាំបួន) ហិកតា ស្ថិតនៅឃុំទំនប់រលក ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ជាដីឯកជនរបស់រដ្ឋតាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum

WGS 1984 ដូចមានផែនទីបង្ហាញទីតាំងដី និងតារាងនិយាមកា ភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ និងអនុវត្តតាមរូបមន្តបែងចែកដូចខាងក្រោម៖

១.ផ្ទៃដីចំនួន ២០% ទំហំ ១៥៩ ហិកតា ៨០ អា ប្រគល់ជូនរដ្ឋបាលខេត្តព្រះសីហនុ។

២.ផ្ទៃដីចំនួន ៨០% ទំហំ ៦៣៩ ហិកតា ២០ អា ផ្ដល់ជាកម្មសិទ្ធិឯកជនជូនក្រុមហ៊ុន C99 international investment (Cambodia) Co.,Ltd. សម្រាប់ធ្វើការអភិវឌ្ឍជាសណ្ឋាគារ វីឡាទំនើប អគារស្នាក់នៅរួមផ្សារទំនើប ភោជនីយដ្ឋាន មជ្ឈមណ្ឌលពាណិជ្ជកម្ម តំបន់សេវាកម្មនានា និងឃ្លាំងដាក់សម្ភារៈ។

**មាត្រា២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៦កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ២០២៣ ✓

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ផែនទីនិងតារាងនិយាមការឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ..១៣៣ អនក្រ.បក..ចុះថ្ងៃទី..២៣....ខែ..មិថុនា...ឆ្នាំ២០២៣




**តារាងនិយាមការភូមិសាស្ត្រ**

Projection, UTM Zone 84N

Datum WGS 1984

| ID | E | N | ID | E | N |
|---|---|---|---|---|---|
| 1 | 350186 | 1188083 | 23 | 355528 | 1187929 |
| 2 | 349872 | 1188211 | 24 | 355271 | 1187909 |
| 3 | 349754 | 1188352 | 25 | 354999 | 1188045 |
| 4 | 350680 | 1189472 | 26 | 352885 | 1187647 |
| 5 | 353029 | 1190271 | 27 | 352984 | 1188005 |
| 6 | 353183 | 1190122 | 28 | 352704 | 1188044 |
| 7 | 353249 | 1190018 | 29 | 352560 | 1188192 |
| 8 | 353222 | 1189929 | 30 | 352054 | 1188099 |
| 9 | 353377 | 1189821 | 31 | 351789 | 1187905 |
| 10 | 353526 | 1189777 | 32 | 351740 | 1187914 |
| 11 | 353476 | 1189547 | 33 | 351650 | 1187883 |
| 12 | 353479 | 1189343 | 34 | 351542 | 1187812 |
| 13 | 353547 | 1189222 | 35 | 351473 | 1187824 |
| 14 | 353801 | 1189000 | 36 | 351376 | 1187742 |
| 15 | 353774 | 1188741 | 37 | 351324 | 1187620 |
| 16 | 353879 | 1188635 | 38 | 351329 | 1187502 |
| 17 | 354617 | 1188546 | 39 | 351308 | 1187480 |
| 18 | 354983 | 1188308 | 40 | 351230 | 1187492 |
| 19 | 355190 | 1188224 | 41 | 351016 | 1187441 |
| 20 | 355569 | 1188155 | 42 | 350942 | 1187475 |
| 21 | 355648 | 1188058 | 43 | 350572 | 1187519 |
| 22 | 355624 | 1187963 | 44 | 350319 | 1187929 |

ផែនទីបង្ហាញទីតាំងដីទំហំ ៧៩៩ ហិកតា ស្ថិតនៅភូមិ១ ឃុំទំនប់រលក ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ក្នុងនោះ ៨០ ភាគរយ ស្នើសុំធ្វើការអភិវឌ្ឍដោយក្រុមហ៊ុន C99 international investment (Cambodia) Co.,Ltd និង ២០ ភាគរយ ប្រគល់ជូនរដ្ឋបាលខេត្តព្រះសីហនុ




តារាងនិយាមការដី

Projection, UTM Zone 84N

Datum WGS 1984

| ID | E | N | ID | E | N |
|---|---|---|---|---|---|
| 1 | 350186 | 1188083 | 23 | 355528 | 1187929 |
| 2 | 349872 | 1188211 | 24 | 355271 | 1187903 |
| 3 | 349754 | 1188352 | 25 | 354939 | 1188045 |
| 4 | 350680 | 1189472 | 26 | 352885 | 1187647 |
| 5 | 353029 | 1190271 | 27 | 352984 | 1188005 |
| 6 | 353183 | 1190122 | 28 | 352704 | 1188044 |
| 7 | 353249 | 1190018 | 29 | 352560 | 1188192 |
| 8 | 353222 | 1189929 | 30 | 352054 | 1188093 |
| 9 | 353377 | 1189821 | 31 | 351789 | 1187905 |
| 10 | 353526 | 1189777 | 32 | 351740 | 1187914 |
| 11 | 353476 | 1189547 | 33 | 351650 | 1187883 |
| 12 | 353479 | 1189343 | 34 | 351542 | 1187812 |
| 13 | 353547 | 1189222 | 35 | 351473 | 1187824 |
| 14 | 353801 | 1189000 | 36 | 351376 | 1187742 |
| 15 | 353774 | 1188741 | 37 | 351324 | 1187620 |
| 16 | 353879 | 1188635 | 38 | 351329 | 1187502 |
| 17 | 354617 | 1188546 | 39 | 351308 | 1187480 |
| 18 | 354983 | 1188308 | 40 | 351230 | 1187492 |
| 19 | 355190 | 1188224 | 41 | 351016 | 1187441 |
| 20 | 355569 | 1188155 | 42 | 350942 | 1187475 |
| 21 | 355648 | 1188058 | 43 | 350572 | 1187519 |
| 22 | 355624 | 1187963 | 44 | 350319 | 1187929 |